ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ **សាលក្រមប្រជារាស្ត្រខ្មែរ**

លេខ : ៥៩ **តុលាការកំពូល**

ចុះថ្ងៃទី១៤-៩-២០០០

**សាលដីកា** បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ២៥ ខែ តុលា

លេខ : ៦៣ ឆ្នាំ២០០០ ដោយមានសមាសភាពក្រុមប្រឹក្សា ជំនុំជំរះដូចតទៅ :

ចុះថ្ងៃទី២៥-១០-២០០០ ១- **ឯកឧត្តម ឃឹម ប៊ុណ្ណា** ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក ប្រាក់ គីមសាន ចៅក្រមរបាយការណ៍

៤- លោក ជីវ កេង ចៅក្រម

៥- លោក ស៊ិន ឌឹម ចៅក្រម

ក្រឡាបញ្ជី

លោក វ៉ាន់ បូរ៉ាត

តំណាងមហាអយ្យការ

**ឯកឧត្តម ជួន ស៊ុនឡេង** អគ្គព្រះរាជអាជ្ញារង

- ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ២១៨ ចុះថ្ងៃទី០៦ ខែកញ្ញាឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៥៩ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០របស់តុលាការកំពូល។

១- ជនជាប់ចោទឈ្មោះចៅ ណារី (ម្ចាស់បណ្តឹងសាទុក្ខ)ភេទស្រី អាយុ៥៨ឆ្នាំ ជាតិខ្មែរ របររកស៊ីគួកជេរផ្ទះ-ដី កើតនៅខេត្តព្រៃវែង ទីលំនៅសព្វថ្ងៃផ្ទះសង់ថ្មី សង្កាត់ទួលស្វាយព្រៃទី1 ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ តាំង តាំង (ស្លាប់) ម្តាយឈ្មោះវ៉ា ឡី ប្តីឈ្មោះវណ្ណ សារ៉េត មានកូន០២នាក់ ។

- មេធាវីការពារលោកទួត លុច

២- ជនជាប់ចោទឈ្មោះតាំង សុខឃាង ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ កើតនៅទីក្រុង ភ្នំពេញ មុខរបរ និស្សិត ទីលំនៅសព្វថ្ងៃផ្ទះលេខ៣DE₀ ផ្លូវលេខ៣៣៨ សង្កាត់ទួលស្វាយព្រៃទី១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះឡៅ ស៊ុំ (រស់) ម្តាយឈ្មោះ លឹម សៀបលី (រស់) ក្រៅឃុំ មេធាវី គ្មាន ។

៣- ជនជាប់ចោទឈ្មោះ ជា គង់ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិចិន មុខរបរលក់ដូរ ។

កើតនៅទីក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃផ្ទះលេខ៩ ផ្លូវលេខ១៣៩ សង្កាត់អូរឫស្សីចាស់ ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ។ ឪពុកឈ្មោះសៀ សៀវប៉ាវ (រស់) ម្តាយឈ្មោះលី លីយ៉ុន (រស់)។ ក្រៅឃុំ មេធាវីគ្មាន ។

៤- ជនជាប់ចោទឈ្មោះ សុខ ចាន់នី ភេទប្រុស អាយុ៣២ ឆ្នាំ ជនជាតិខ្មែរ មុខរបរ វាយកុំព្យូទ័រ កើតនៅទីក្រុងភ្នំពេញ ។ ទីលំនៅសព្វថ្ងៃផ្ទះលេខ១៨៦$E_3$ ផ្លូវលេខ១១០ សង្កាត់ផ្សារ ចាស់ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ សុខ ចាន់មុន្នី (រស់) ម្តាយឈ្មោះតាំង សុខ-ហៀង (រស់) ប្រពន្ធឈ្មោះ ដួង ចាន់មុន្នី មានកូន០២នាក់ ។ នៅក្រៅឃុំ មេធាវីគ្មាន ។

ពីបទ : ប្រើ និង ធ្វើអត្តសញ្ញាណប័ណ្ណ និង លិខិតឆ្លងដែនក្លែងក្លាយ ប្រព្រឹត្តនៅក្រុង ភ្នំពេញ ក្នុងឆ្នាំ២០០០ ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៨-០៧-២០០០ របស់ឈ្មោះ ចៅ ណារី ប្តឹងពីឈ្មោះ ចាន់ នី ពីបទ ធ្វើលិខិតអត្តសញ្ញាណប័ណ្ណ ក្លែងក្លាយដោយបញ្ជាក់ថា កាលពីថ្ងៃទី២៧-៣-២០០០ វេលាម៉ោង៨$^H$ ខ្លួនបានយកអត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែន ទៅពឹងឈ្មោះខាងលើជួយធ្វើដោយអោយតំលៃ១៣០$ ដើម្បីធ្វើលិខិតលាសញ្ជាតិ ស្របច្បាប់តែផ្ទុយទៅវិញឈ្មោះនេះ បែរជាយកលិខិតលាសញ្ជាតិ មិនត្រឹមត្រូវមកអោយ ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៨-០៧-២០០០របស់ឈ្មោះតាំង សុខឃាង ប្តឹងពីឈ្មោះចៅ ណារី (ហៅយាយបារាំង) ពីបទធ្វើលិខិតលាសញ្ជាតិក្លែងក្លាយអោយឈ្មោះជា គង់ ដោយបញ្ជាក់ថា កាលពីដើមខែមេសា ឆ្នាំ២០០០ ឈ្មោះ សៀវ លីលី ជាម្តាយជា គង់ បានពឹងអោយខ្លួនធ្វើបែបបទលាសញ្ជាតិ ខ្លួនក៏ទៅពឹងយាយបារាំងអោយជួយធ្វើដោយអះអាងថា គាត់ធ្វើអោយត្រឹមត្រូវតាមច្បាប់ តែផ្ទុយទៅវិញ ឯកសារនោះក្លែងក្លាយ ។

តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ សុខ ចាន់នីថា នៅខែមិនា ឆ្នាំ២០០០ ខ្លួនបានទទួលឯកសារពីយាយបារាំង ដែលមានកិច្ចសន្យាជួលផ្ទះលិខិតផ្ទេរសិទ្ធិ កាតហ្វីសឹតវាយជាភាសារអង់គ្លេស និងភាសារខ្មែរ គំរូត្រាមូល ត្រាឈ្មោះ ហត្ថលេខារបស់ឯកឧត្តម ស ខេង និងឯកឧត្តមយូ ហុកគ្រីចំពោះគំរូត្រា ត្រាឈ្មោះ ហត្ថលេខារបស់ឯកឧត្តម គឺយាយបារាំងបានយកទៅអោយខ្លួន ជួយស្កេនបញ្ចូលក្នុងក្រដាសមួយសន្លឹក ដែលមានទំរង់ជាក្រដាស់សំរាប់វាយអត្ថបទ ហើយក្នុងនោះដែរ គាត់បានយកគំរូត្រា ហត្ថលេខាឈ្មោះ សុទ្ធ ពុំមានអត្ថបទអ្វីឡើយ ហើយគាត់និយាយប្រាប់ខ្លួនថា ជួយស្កេនគំរូនេះចូលក្នុងក្រដាសមួយសន្លឹក ដើម្បីអោយគាត់យកមកបំពេញអត្ថបទដោយខ្លួនឯង ពេលខ្លួនស្កេនជូនគាត់ហើយគាត់ក៏យកឯកសារទាំងនោះមកវិញ ហើយគាត់យកគំរូដើមហែកចោល គាត់យកក្រដាស់ដែលស្កេនហើយនោះ ។ បន្ទាប់មកយាយបារាំងបានអោយលុយទៅម្ចាស់ហាង២ដុល្លា រួចគាត់

បញ្ហាអោយខ្លួនលប់គំរូដែលថតក្នុងComputer ចោល។ ចំពោះការវាយនិងការធ្វើឯកសារលាសញ្ជាតិ និងអត្តសញ្ញាណប័ណ្ណនេះខ្លួនពុំបានដឹងឡើយ ។

បានឃើញដីកាបញ្ជូនរឿងអោយស៊ើបសួរលេខ១៧៦៧ ចុះថ្ងៃទី១២-៧-២០០០របស់តំណាងអយ្យការ អមតុលាការក្រុងភ្នំពេញ បានសម្រេចចោទប្រកាន់ឈ្មោះ ជា គង់ ភេទប្រុសអាយុ៣០ឆ្នាំ តាំង សុខឃាង ភេទប្រុស អាយុ២៦ឆ្នាំ ចៅ ណារី ភេទស្រី អាយុ៥៨ឆ្នាំ សុខ ចាន់នី ភេទប្រុស អាយុ៣២ឆ្នាំ និងគូរកន ពីបទ : ប្រើនិងធ្វើអត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែនក្លែងក្លាយ ប្រព្រឹត្តនៅភ្នំពេញ កាលពីឆ្នាំ២០០០ តាមមាត្រា៤៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

បានឃើញដីកាសំរេចរបស់ចៅក្រមស៊ើបអង្កេត តុលាការក្រុងភ្នំពេញ បានសំរេចថា :

១-ឃុំខ្លួនឈ្មោះ ចៅ ណារី តាមដីកាឃុំខ្លួនលេខ៦៩៩ ចុះថ្ងៃទី១២-៧-២០០០។

២-ឃុំខ្លួនឈ្មោះ សុខ ចាន់នី តាមដីកាឃុំខ្លួនលេខ៧០០ ចុះថ្ងៃទី១២-៧-២០០០

៣-ឃុំខ្លួនឈ្មោះ តាំង សុខឃាង តាមដីកាឃុំខ្លួនលេខ៧០៧ ចុះថ្ងៃទី១៣-៧-២០០០ ។

៤-ឃុំខ្លួនឈ្មោះ ជា គង់ តាមដីកាឃុំខ្លួនលេខ៧០៨ ចុះថ្ងៃទី១៣-៧-២០០០ ។

ពីបទ : ប្រើ និងធ្វើអត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែន ក្លែងក្លាយ ប្រព្រឹត្តនៅភ្នំពេញ កាលពីឆ្នាំ២០០០ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ១៨"ឆ" ចុះថ្ងៃទី០៧-៨-២០០០ របស់លោកចុង អៀវហេង ជាមេធាវីការពារអោយឈ្មោះ ចៅ ណារី លើដីកាឃុំខ្លួនលេខ៦៩៩ចុះថ្ងៃទី១២-៧-២០០០ របស់ចៅក្រម ស៊ើបអង្កេត ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ២១"ឆ" ចុះថ្ងៃទី១៨-៨-២០០០ របស់លោក ទូត លុច ជាមេធាវីការពារអោយឈ្មោះ ចៅ ណារី លើដីកាឃុំខ្លួនលេខ៩៥០៣តព្រ ចុះថ្ងៃទី១៧-៨-២០០០ របសចៅក្រមស៊ើបអង្កេត ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ២៤"ឆ" ចុះថ្ងៃទី២៣-៨-២០០០ របស់លោក ឡៅ ស៊ុំ ជាឪពុករបស់ឈ្មោះតាំង សុខឃាង លើដីកាសំរេចលេខ៩៦២៤តព្រ ចុះថ្ងៃទី២៣-៨-២០០០ របស់ចៅក្រមស៊ើបអង្កេត ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ២៩"ឆ" ចុះថ្ងៃទី០៥-៩-២០០០ របស់លោក ឌី បូរីម៉ា ជាមេធាវីការពារអោយឈ្មោះ សុខ ចាន់នី លើដីកាសំរេចលេខ៩៨៣៥ តព្រ ចុះថ្ងៃទី០៤-៩-២០០០ របស់ចៅក្រមស៊ើបអង្កេត ។

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា : ដោយរឿងមិនទាន់បានទទួលការស៊ើបអង្កេតវែងឆ្ងាយ សន្និដ្ឋានចំពោះសាលាឧទ្ធរណ៍ បដិសេធការអនុញ្ញាត្តអោយនៅក្រៅឃុំបណ្តោះអាសន្ន ។

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២១៨ ចុះថ្ងៃទី០៦-៩-២០០០ ដែលមានខ្លឹមសារសេចក្តីសំរេចដូចតទៅ :

១-មិនទទួលជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៧-៨-២០០០ របស់លោកមេធាវីឈ្មោះចុង អៀវហេង ដោយបណ្តឹងឧទ្ធរណ៍នេះធ្វើឡើងហួសកំណត់ច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៨-៨-២០០០របស់មេធាវីឈ្មោះទូត លុចទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុស នឹងគតិច្បាប់ ។

៣-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៣-៨-២០០០ របស់ឈ្មោះឡៅ ស៊ុំ និងបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៥-៩-២០០០ របស់មេធាវីឈ្មោះឌី ប៊ូរីម៉ា ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

៤-តម្កល់ដីកាសំរេចលេខ៩៥០៣ ចុះថ្ងៃទី១៧-៨-២០០០របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៥-បដិសេធដីកាសំរេចលេខ៥៦២៤ ចុះថ្ងៃទី២៣-៨-២០០០ និងដីកាសំរេចលេខ៥៨៣៥ ចុះថ្ងៃទី០៤-៩-២០០០ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៦-សំរេចអោយឈ្មោះតាំង សុខឃាង និងសុខ ចាន់នី នៅក្រៅឃុំបណ្តោះអាសន្ន

៧-បង្គាប់អោយដោះលែងឈ្មោះតាំង សុខឃាង និងសុខ ចាន់នី ពីមន្ទីរឃុំឃាំងជាបន្ទាន់ ប្រសិនបើជនជាប់ចោទរូបនេះពុំមានជាប់ឃុំឃាំងពីបទអ្វីផ្សេងទៀតទេ ។

៨-សាលដីកានេះមានអនុភាព អនុវត្តភ្លាម១ ទោះជាមានបណ្តឹងសាទុក្ខក៏ដោយ ។

៩-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះតាំង សុខឃាង មេធាវីការពារឈ្មោះចៅ ណារី មេធាវីការពារឈ្មោះសុខ ចាន់នី នឹងឈ្មោះឡៅ ស៊ុំ កំបាំងមុខជនជាប់ចោទ ចៅ ណារី និងសុខ ចាន់នី ។ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់។

បានឃើញបណ្តឹងសាទុក្ខលេខ៨៣ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០០ របស់លោក ទូត លុចជាមេធាវីការពារអោយឈ្មោះ ចៅ ណារី ប្តឹងមិនសុខចិត្តនឹងសាលដីកានេះ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០០ របស់ម្ចាស់បណ្តឹងសាទុក្ខ ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : លទ្ធផលនៃការ

ស៊ើបអង្កេតពុំបង្ហាញថា ឈ្មោះ ចៅ ណារី បានធ្វើអត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែនក្លែងក្លាយ អោយជនជាប់ចោទ ឈ្មោះ ជា គង់ ឡើយ ។

- ជនជាប់ចោទឈ្មោះ ចៅ ណារី មានមុខរបរ មានទីលំនៅពិតប្រាកដ មានការធានា ត្រឹមត្រូវ ព្រមទាំងមាន ជម្ងឺប្រចាំកាយ ទាមទារការព្យាបាល ពីគ្រូពេទ្យជំនាញ ដូច្នេះពុំអាចប្រើឥទ្ធិ ពល ទៅលើសាក្សី និងបង្កឧបសគ្គដល់ការស៊ើបអង្កេតឡើយ ។

- ការសំរេចសេចក្តី របស់សាលាឧទ្ធរណ៍ គឺមានលក្ខណៈខុសឆ្គង ទៅនឹងគតិច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ចៅ ណារី នាពេលសវនាការថា : នាងខ្ញុំពិតជាពុំបានធ្វើអត្តសញ្ញាណប័ណ្ណក្លែងក្លាយទេ ។ ព្រោះថា កាលពីថ្ងៃទី២៧-៣-២០០០ វេលាម៉ោង៨[H] នាងខ្ញុំបានយកអត្តសញ្ញាប័ណ្ណ និងលិខិតឆ្លងដែនទៅពីងឈ្មោះចាន់ នី អោយជួយធ្វើដោយអោយតំលៃ១៣០ USD ដើម្បីធ្វើលិខិតលាសញ្ជាតិស្របច្បាប់ តែផ្ទុយទៅវិញឈ្មោះនេះបែរជាយកលិខិតលាសញ្ជាតិមិនត្រឹមត្រូវ មកអោយនាងខ្ញុំ ។ នាងខ្ញុំសូមសំណូមដល់ក្រុមប្រឹក្សាជំនុំជំរះ មេត្តារកយុត្តិធម៌ដល់នាងខ្ញុំផង ។

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់ លោក ទូត លុច នៅពេលជំនុំជំរះថា : កាលដែលតុលាការក្រុងភ្នំពេញ និង សាលាឧទ្ធរណ៍សំរេចឃុំខ្លួនឈ្មោះ ចៅ ណារី ជាបណ្តោះអាសន្ន នោះជាការបំពានទៅនឹងមាត្រាទី ១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលទាំងស្រុង ។ ដូចនេះតាមផ្លូវច្បាប់តុលាការគប្បីអោយឈ្មោះចៅ-ណារី បាននៅក្រៅឃុំបណ្តោះអាសន្នស្របតាមមាត្រា១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានស្តាប់តំណាងមហាអយ្យការថា : ពុំមានអ្វីបន្ថែមទៀតទេ សូមតម្កល់សេចក្តីសន្និដ្ឋាន នៅដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចំលើយ របស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី ជនជាប់ចោទ

- ក្រោយពីបាន ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៨៣ ចុះថ្ងៃទី១១-៩-២០០០ របស់លោកទូត លុច មេធាវីការពារអោយឈ្មោះ ចៅ ណារី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចតម្កល់ដីកាសំរេចលេខ៩៥០៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០០ របស់ចៅក្រមស៊ើបអង្កេត តុលាការក្រុងភ្នំពេញ ទុកជាបានការ ដោយលើកយកបទល្មើស ក្លែងលិខិតបញ្ជាក់លាសញ្ជាតិ របស់ជនជាប់ចោទឈ្មោះ ជា គង់ មកពិចារណានោះ គឺជាការភ័ន្តច្រឡំ ពីព្រោះថា :

+ អំពើល្មើស ដែលព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់លើជនជាប់ចោទឈ្មោះចៅ-ណារី តាមអំណាចដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ១៧៦៧ ចុះថ្ងៃទី១២-៧-២០០០ គឺជាបទល្មើសប្រើ និងធ្វើអត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែនក្លែងក្លាយ ដែលត្រូវផ្តន្ទាទោស តាម បញ្ញត្តិមាត្រា៤៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ហើយដីកាឃុំខ្លួនជនជាប់ចោទលេខ៦៨៩ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០០ ក៏យោងទៅលើអំពើល្មើសនេះដែរ ប៉ុន្តែឈ្មោះចៅ ណារី ពុំមានពាក់ព័ន្ធក្នុងបទល្មើសនេះទេ ចំណែកបទល្មើសក្លែងលិខិតបញ្ជាក់លាសញ្ជាតិ របស់ឈ្មោះជា គង់ ដែលពាក់ព័ន្ធដល់ឈ្មោះ ចៅ ណារី ព្រះរាជអាជ្ញាពុំទាន់ធ្វើការចោទប្រកាន់នៅឡើយ ។ ដូច្នេះចៅក្រមស៊ើបអង្កេត ពុំមានសមត្ថកិច្ចឃុំខ្លួនជនណាម្នាក់ពីបទអ្វីមួយ ដោយពុំមានការផ្តើមចោទប្រកាន់ពីព្រះរាជអាជ្ញាទេ។

- យល់ឃើញថា ជនជាប់ចោទឈ្មោះចៅ ណារី ជាមេគ្រួសារមានមុខរបរ មានទីលំនៅ ពិតប្រាកដជរា មានការធានាត្រឹមត្រូវព្រមទាំងមានជម្ងឺប្រចាំកាយ ទាមទារការព្យាបាលពីគ្រូពេទ្យជំនាញ ដូច្នេះតាមមាត្រា ១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល តុលាការអាចសំរេចឱ្យជនជាប់ចោទ នៅក្រៅឃុំបណ្តោះអាសន្នបាន ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ២១៨ ចុះថ្ងៃទី០៦-៩-២០០០ ត្រង់ចំណុចទី៤ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ និងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី ចំពោះមុខជនជាប់ចោទ**

១- ទទួលបណ្តឹងសាទុក្ខលេខ៨៣ ចុះថ្ងៃទី១១-៩-២០០០ របស់លោកទូត លុច មេធាវីការពារឱ្យជនជាប់ចោទ ឈ្មោះចៅ ណារី ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២- ទុកជាមោឃៈ ចំនុចទី៤ នៃសាលដីកាព្រហ្មទណ្ឌលេខ២១៨ ចុះថ្ងៃទី០៦-៩-២០០០ របស់សាលាឧទ្ធរណ៍ ចោលជាអសារបង់ ។

៣- បង្គាប់អោយដោះលែង ជនជាប់ចោទឈ្មោះចៅ ណារី អោយនៅក្រៅឃុំ ជាបណ្តោះ អាសន្ន រង់ចាំតុលាការសំរេចដល់អង្គសេចក្តីប្រសិន បើឈ្មោះនេះពុំមានជាប់ឃុំ ពីបទផ្សេងទៀតទេ

៤- បញ្ជូនសំណុំរឿង ព្រហ្មទណ្ឌលេខ៩៩ ចុះថ្ងៃទី១៤-៩-២០០០ របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីអនុវត្តតាមនីតិវិធី ។

៥- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០០។